# ក្របខណ្ឌគោលនយោបាយការទារដោះស្រាយផលប៉ះពាល់

## សេចក្តីសង្ខេប

## សេចក្តីផ្តើម និងផ្នែកសំខាន់ៗរបស់គម្រោង

១. គោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDG) ស្តីពីទឹកស្អាត និងអនាម័យមានឧបសគ្គយ៉ាងច្រើនដល់ប្រទេសកម្ពុជា នៅពេលពិនិត្យលើការពង្រីកការទទួលបាន ការកាត់បន្ថយគម្លាត និងការបង្កើនគុណភាពសេវា។ នៅក្នុងប្រទេសកម្ពុជា លទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹកដែលមានភាពល្អប្រសើរ គឺមាន ៧៦% និងអនាម័យមាន ៤២% នៅក្នុងឆ្នាំ២០១៥ ដែលលទ្ធភាពនេះទាបជាងប្រទេសផ្សេងៗទៀតនៅក្នុងតំបន់។ ប្រជាពលរដ្ឋប្រមាណជា ២៤% ប៉ុណ្ណោះមានលទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹកស្អាតដែលមានការគ្រប់គ្រងដោយសុវត្ថិភាព នៅក្នុងឆ្នាំ២០១៥[1]។ ការផ្តល់ទឹកតាមរយៈបំពង់ទឹកសុវត្ថិភាពចូលបរិវេណលំនៅឋាន និងការគ្រប់គ្រងសំណល់រាវប្រកបដោយប្រសិទ្ធភាព (ជាពិសេសក្នុងតំបន់ប្រជុំជន) នឹងរួមចំណែកយ៉ាងខ្លាំងដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព។ ទោះជាយ៉ាងនេះក្តី អត្រាគ្របដណ្តប់កម្រិតទាបនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ កង្វះហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការគ្រប់គ្រងទឹកស្អុយ និងកង្វះប្រព័ន្ធគ្រប់គ្រងពាក់ព័ន្ធ គឺជាបញ្ហាប្រឈមដ៏ធំដល់ការឈានទៅសម្រេចឱ្យទាន់ពេលវេលានៃគោលដៅអភិវឌ្ឍន៍ដោយចីរភាព។

២. គោលបំណងអភិវឌ្ឍន៍នៃគម្រោងនេះ គឺដើម្បីលើកកម្ពស់លទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ និងសេវាអនាម័យដែលមានភាពប្រសើរ និងពង្រឹងការបំពេញការងារប្រតិបត្តិនៃអ្នកផ្តល់សេវានៅក្នុងក្រុង ឬតំបន់ដែលបានជ្រើសរើស។ គម្រោងនេះមានគោលបំណងបំពេញបន្ថែមកម្មវិធីនានាដែលកំពុងអនុវត្តន៍ និងផ្អែកតាមផែនការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ ចំពោះការផ្គត់ផ្គង់ទឹកស្អាតទីតាំងគោលដៅ នឹងផ្តោតការយកចិត្តទុកដាក់លើតំបន់ដែលមានកង្វះខាតការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់។ ដោយផ្តោតលើទីប្រជុំជនខេត្ត និងក្រុងសំខាន់ៗដែលបានជ្រើសរើស គម្រោងនេះនឹងផ្តល់ការគាំទ្រដល់ការពង្រីកនៃការផ្តល់សេវាដែលកំពុងដំណើរនាពេលបច្ចុប្បន្នទៅកាន់តំបន់ក្បែរៗនោះ ដើម្បីបង្កើនអត្រាគ្របដណ្តប់នៃការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់ប្រសិទ្ធភាព និងនិរន្តរភាពរបស់អ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត។ ចំពោះ បញ្ហាអនាម័យ ការយកចិត្តទុកដាក់ជាចម្បងនោះ គឺត្រូវលើកកម្ពស់ឱ្យបានទូលំទូលាយនូវមុខងារនៃប្រព័ន្ធគ្រប់គ្រងទឹកកខ្វក់ដែលមានស្រាប់ក្នុងក្រុងសៀមរាប តាមរយៈការតភ្ជាប់ប្រព័ន្ធលូទឹកកខ្វក់ដោយផ្ទាល់ដើម្បីបង្ហូរទឹកកខ្វក់ចេញពីលំនៅឋាន។

៣. គម្រោងនេះមានសមាសភាគសំខាន់ៗចំនួនពីរ។ សមាសភាគទីមួយនឹងផ្តល់ហិរញ្ញវត្ថុសម្រាប់អនុវត្តន៍សកម្មភាពនានាដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្ត ក្នុងក្រុងសែនមនោរម្យ (ខេត្តមណ្ឌលគិរី) ក្រុង

[1] WHO/UNICEF JMP, 2017. Note that the estimate for safely managed sanitation is not available.

ស្ទោង (ខេត្តកំពង់ធំ) ស្រុកភ្នំព្រឹក (ខេត្តបាត់ដំបង) និងទីតាំងផ្សេងៗទៀតដែលត្រូវបានកំណត់ធ្វើឡើង នៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោង។ សមាសភាគទីពីរនឹងផ្តល់ហិរញ្ញវត្ថុសម្រាប់អនុវត្តសកម្មភាព សម្រាប់កែលម្អបញ្ហាអនាម័យក្នុងក្រុងសៀមរាប និងតំបន់ផ្សេងៗទៀត។

៤. ចំពោះការផ្គត់ផ្គង់ទឹកស្អាត បើទោះបីជាការសិក្សាគ្រោងប្លង់លម្អិតកំពុងតែដំណើរការក៏ដោយ ក៏ទីតាំងពង្រីកបណ្តាញផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងសែនមនោរម្យត្រូវបានកំណត់ជាបឋមរួចរាល់ហើយ។ ដោយសារតែការងារនេះជាការងារតូចតាច ដូចជាការជីកដីសម្រាប់ដាក់បំពង់ផ្គត់ផ្គង់ទឹកស្អាតក្នុងជម្រៅប្រមាណជា ០,៧៥ ម៉ែត្រ និងការតម្លើងម៉ូទ័របូមទឹកក្នុងទីតាំងចំនួនបីប៉ុណ្ណោះ ដូច្នេះគម្រោងនេះមានផលប៉ះពាល់រយៈពេលខ្លីប៉ុណ្ណោះក្នុងអំឡុងពេលសាងសង់។ គម្រោងនេះក៏នឹងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកថ្មីៗ ដែលនឹងកំណត់ឡើង នៅក្នុងទីតាំងសំខាន់ៗក្នុង ក្រុងសែនមនោរម្យ ក្រុងស្ទោង ស្រុកភ្នំព្រឹក និងទីតាំង/ក្រុង/តំបន់នានា ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង។

៥. ចំពោះការគ្រប់គ្រងលូទឹកកខ្វក់ គឺផ្តោតការយកចិត្តទុកដាក់លើការគាំទ្រដល់ការអភិវឌ្ឍ និងសាងសង់បណ្តាញលូរង ដែលត្រូវតភ្ជាប់ទៅប្រព័ន្ធលូមេ ក្នុងទីក្រុងសៀមរាប ដើម្បីឱ្យលំនៅឋាន និងទីតាំងជំនួញអាចតភ្ជាប់ដោយផ្ទាល់ទៅនឹងប្រព័ន្ធលូ។ ដើម្បីកាត់បន្ថយផលប៉ះពាល់លើសង្គម បណ្តាញលូរងបន្ថែមក្នុងក្រុងសៀមរាបនឹងត្រូវបានសាងសង់ ភាគច្រើននៅតាមប្រព័ន្ធផ្លូវដែលមានស្រាប់។ ដូច្នេះ ក្រោមសមាសភាគនេះ ពុំមានតម្រូវការទិញដីមកប្រើប្រាស់នោះទេ បើទោះបីជាអាចមានការជម្លៀសប្រជាជនបណ្តោះអាសន្នមួយចំនួនក៏ដោយ ជាពិសេសក្នុងតំបន់ផ្សាររាត្រី។

៦. នៅក្នុងតំណាក់កាលនេះ វិសាលភាពនៃលទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត ឬការធ្វើអំណោយដីដោយស្ម័គ្រចិត្តមិនទាន់ដឹងនៅឡើយទេ ពីព្រោះការរៀបចំលម្អិត និងទីតាំងពិតប្រាកដរបស់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតថ្មីៗ (ស្ថិតក្នុងសមាសភាគទី១) នឹងត្រូវកំណត់ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង និងការសិក្សាគ្រោងប្លង់លម្អិតសម្រាប់បណ្តាញលូ ក្នុងទីក្រុងសៀមរាប (ក្នុងសមាសភាគទី២) ក្នុងតំបន់ផ្សាររាត្រីមិនទាន់បានបញ្ចប់នៅឡើយ។ ដូច្នេះ ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) ត្រូវបានបង្កើតឡើងដើម្បីប្រើជាឯកសារគោលមុនពេលអនុវត្តការងារ សម្រាប់កាត់បន្ថយផលប៉ះពាល់អវិជ្ជមានសំខាន់ៗ ដោយសារតែ (ក)-លទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត ឬ (ខ)-ការធ្វើអំណោយដីដោយស្ម័គ្រចិត្ត ឬ (គ)-ការរំខានដល់សកម្មភាពចិញ្ចឹមជីវិត។ ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ត្រូវធ្វើឡើងឱ្យស្របតាម (១)-គោលនយោបាយ របស់ធនាគារពិភពលោកស្តីពីការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្ត (OP/BP 4.12) និង (២)-ច្បាប់កម្ពុជាស្តីពីអស្សាមិករណ៍ និងគោលនយោបាយ និងនីតិវិធីពាក់ព័ន្ធផ្សេងៗទៀតនឹងត្រូវយកមកអនុវត្តនៅគ្រប់ផ្នែក និងសកម្មភាពទាំងអស់របស់គម្រោង (ក្នុងនោះរួមទាំងនីតិវិធីប្រតិបត្តិស្តង់ដារចុងក្រោយរបស់រដ្ឋាភិបាល)។

## ការពិនិត្យឡើងវិញពីក្របខណ្ឌច្បាប់

៧. ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះត្រូវបានរៀបចំឡើងស្របតាម OP/BP 4.12 របស់ធនាគារពិភពលោក ស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត និងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងប្រទេសកម្ពុជា ជាពិសេសរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់ភូមិបាល និងច្បាប់ស្តីពីអស្សាមិករណ៍។ គម្លាតរវាងក្របខណ្ឌច្បាប់ទាំងពីរ ពោលគឺរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោកត្រូវបានវិភាគ ហើយវិធានការបំពេញចន្លោះខ្វះខាតត្រូវបានស្នើឡើង ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអតិបរមាលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

៨. ច្បាប់ស្តីពីអស្សាមិករណ៍ដែលបានដាក់ឱ្យប្រើប្រាស់នៅក្នុង ឆ្នាំ២០១០ ចែងពីគោលការណ៍យន្តការ និងនីតិវិធីអំពីអស្សាមិករណ៍ និងកំណត់ពីការផ្តល់សំណងដោយត្រឹមត្រូវ និងយុត្តិធម៌ដល់គម្រោងពង្រីកការសាងសង់ ការស្តារឡើងវិញ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចំពោះសាធារណជន និងផលប្រយោជន៍ជាតិ និងការអភិវឌ្ឍកម្ពុជា។ ច្បាប់ស្តីពីអស្សាមិករណ៍ដែលភាគច្រើនស៊ីសង្វាក់គ្នាជាមួយនឹងគោលការណ៍ចម្បងនៃគោលនយោបាយតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត (OP/BP 4.12) នឹងត្រូវប្រើប្រាស់ក្នុងគម្រោងសម្រាប់ចំណែកដ៏ចាំបាច់នៃការកាន់កាប់អចលនទ្រព្យ ឬសិទ្ធិជាក់ស្តែងលើអចលនទ្រព្យរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ឬនីតិបុគ្គលសាធារណៈ រួមទាំងដីធ្លី អគារ និងដំណាំ និងសម្រាប់ការសាងសង់ ការស្តារឡើងវិញ ឬការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

៩. គោលបំណងរួមនៃគោលនយោបាយធនាគារ OP/BP 4.12 គឺដើម្បីបញ្ចៀស ឬកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ និងស្វែងរកជម្រើសក្នុងការរៀបចំគម្រោងដែលមានភាពសមស្របបំផុត។ ក្នុងករណីដែលមិនអាចបញ្ចៀសបានទេ សកម្មភាពតាំងទីលំនៅគួរតែត្រូវបានពិចារណា និងអនុវត្តន៍ដោយចាត់ទុកជាកម្មវិធីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព តាមរយៈការផ្តល់ធនធានវិនិយោគឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យបុគ្គលដែលត្រូវបានបំលាស់ទីដោយសារគម្រោងបានទទួលផលប្រយោជន៍ពីគម្រោង។ បុគ្គលដែលត្រូវបានផ្លាស់ប្តូរទីលំនៅគួរតែទទួលបានការពិគ្រោះយោបល់ឱ្យបានពេញលេញ និងគួរមានឱកាសចូលរួមក្នុងការរៀបចំផែនការ និងការអនុវត្តកម្មវិធីតាំងទីលំនៅ។ បុគ្គលដែលត្រូវបានផ្លាស់ប្តូរទីលំនៅគួរទទួលបានជំនួយដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងកម្រិតរស់នៅ ឬយ៉ាងហោចណាស់ជួយពួកគេជាក់ស្តែងឱ្យរស់នៅក្នុងកម្រិតមួយស្មើនឹងកម្រិតមុនផ្លាស់ប្តូរទីលំនៅ ឬកម្រិតជីវភាពនៅមុនចាប់ផ្តើមអនុវត្តន៍គម្រោង ពោលគឺកម្រិតខ្ពស់ជាងមុនពេលអនុវត្តន៍គម្រោង។

## ក្របខណ្ឌគោលនយោបាយអំពីលទ្ធកម្មដីធ្លី និងគោលនយបាយសំណង

១០. **គោលបំណង៖** គម្រោងមុនៗ និងស្រដៀងៗគ្នាដែលត្រូវបានអនុវត្តន៍ដោយ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពុំមានលទ្ធកម្មដី ពីព្រោះហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងអស់ត្រូវបានសាងសង់ឡើងនៅ

លើដីដែលជាកម្មសិទ្ធិរបស់មន្ទីរ ឬជាដីរបស់រដ្ឋ។ ស្រដៀងគ្នានេះដែរ ចំពោះក្រសួងសាធារណការ និងដឹកជញ្ជូន បណ្តាញលូរងដែលត្រូវបានសាងសង់តាមរយៈគម្រោងស្រដៀងគ្នានេះ គឺស្ថិតក្នុងផ្នែកខាងក្នុងនៃផ្លូវដែលមានស្រាប់។ ដូច្នេះ ក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់នេះត្រូវបានរៀបចំឡើងសម្រាប់ប្រើជាផ្នែកមួយនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) សម្រាប់ គម្រោងធ្វើឱ្យប្រសើរឡើងការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (WaSSIP) សម្រាប់ផ្តល់ការណែនាំដល់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរសាធារណការ និងដឹកជញ្ជូន ដើម្បីធ្វើការសម្របសម្រួលក្នុងស្ថានភាពដែលតំបន់គោលដៅដែលបានស្នើឡើងអាចតម្រូវឱ្យមានការប្រើប្រាស់ដីបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ និងផ្អែកលើការផ្តល់ដីឱ្យដោយស្ម័គ្រចិត្ត ឬលទ្ធកម្មដីមិនស្ម័គ្រចិត្តដែលជាតម្រូវការចាំបាច់សម្រាប់ការសាងសង់ក្នុងតំបន់គោលដៅ។ ចំណុចនេះក៏នឹងអាចអនុវត្តន៍បានផងដែរចំពោះដីដែលស្ថិតក្នុងតម្រូវការមុនការផ្តល់ហិរញ្ញវត្ថុពីធនាគារដល់ទីតាំងនានាដែលទទួលបានការគាំទ្រពីគម្រោង។ ដូច្នេះ ក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់នេះ ត្រូវបានរៀបចំឡើងសម្រាប់កំណត់ពីគោលនយោបាយ និងនីតិវិធីក្នុងគោលបំណងទប់ស្កាត់ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពាក់ព័ន្ធនឹងលទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត និងការតាំងទីលំនៅដោយសារតែការងារសាងសង់ដែលត្រូវអនុវត្តន៍។ ក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់នេះ ក៏កំណត់ពីដំណើរការដែលចាំបាច់ត្រូវតែអនុវត្តដោយការយកចិត្តទុកដាក់ខ្ពស់ទាក់ទងនឹងការផ្តល់ដីដោយស្ម័គ្រចិត្ត។

១១. **គោលការណ៍៖** ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិជាធរមានរបស់កម្ពុជា ចំណុចភាគច្រើនបំផុតនៃការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត (OP/BP 4.12) ត្រូវបានបញ្ជាក់យ៉ាងគ្រប់គ្រាន់នៅក្នុងច្បាប់នៃប្រទេសកម្ពុជា ជាពិសេសច្បាប់ស្តីពីអស្សាមិករណ៍។ គោលបំណងចម្បងនៃគម្រោងនេះទាក់ទងនឹងលទ្ធកម្មដី និងទ្រព្យសម្បត្តិគឺដើម្បីជួយឱ្យប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងក្នុងការស្តារជីវភាពរស់នៅរបស់ពួកគេ យ៉ាងហោចណាស់ដល់កម្រិតមួយស្មើនឹងកម្រិតមុនអនុវត្តគម្រោង។ គោលការណ៍ជាក់លាក់ដែលគម្រោងត្រូវអនុវត្តន៍ មានដូចខាងក្រោម៖

(i) ការកសាងស្ថានីយប្រព្រឹត្តកម្មទឹកស្អាតថ្មី ការតពង្រីកបណ្តាញបំពង់ផ្គត់ផ្គង់ទឹកស្អាត ការសាងសង់បណ្តាញលូរង និងការតម្លើងម៉ូទ័របូមទឹកគឺដើម្បីបញ្ចៀសលទ្ធកម្មដីដែលជាកម្មសិទ្ធិឯកជន និងការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន រួមទាំងជនជាតិដើមភាគតិច។

(ii) ធានាថា បទដ្ឋានរៀបចំកាត់បន្ថយជាអតិបរមា នូវតម្រូវការដែលនាំដល់ការរឹតត្បិតលើការប្រើប្រាស់ដីនៅតំបន់ជិតៗនោះ។

(iii) រៀបចំបង្កើតនីតិវិធីដោយយុត្តិធម៌ និងមានតម្លាភាព ដូចមានកំណត់ក្នុងតារាងបញ្ជាក់សិទ្ធិលើទ្រព្យសម្បត្តិនៃក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់ ដើម្បីកំណត់គោល

នយោបាយសំណងសម្រាប់ (១)-ការបាត់បង់ដី និង/ឬ ទ្រព្យសម្បត្តិមួយរយៈក្នុងអំឡុងពេលសាងសង់ (២)-លទ្ធកម្មអចិន្ត្រៃយ៍ នៃដី និង/ឬទ្រព្យសម្បត្តិ និង(៣)-ការរឹតត្បិតលើការប្រើប្រាស់ដី។

(iv) តម្រូវការដី (ឬសិទ្ធិប្រើប្រាស់ដី) តាមរយៈការចរចាចុះកិច្ចព្រមព្រៀង និងប្រើប្រាស់អំណាចពិសេស តែនៅពេលជម្រើសចុងក្រោយបំផុតប៉ុណ្ណោះ។

(v) បន្ទាប់ពីបញ្ចប់ការសាងសង់ ត្រូវលុបដី ឬកាយដីចេញវិញអោយដូចស្ថានភាពដើមមុនពេលសាងសង់ ក្នុងករណីមានការរំខានជាបណ្តោះអាសន្នក្នុងពេលសាងសង់ ដើម្បីឱ្យម្ចាស់ដី/អ្នកប្រើប្រាស់/អ្នកជួលអាចចាប់ផ្តើមសកម្មភាពដូចនៅមុនពេលអនុវត្តន៍គម្រោងឡើងវិញ។

(vi) ត្រូវជូនព័ត៌មានឱ្យបានពេញលេញដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង និងខ្នងផ្ទះ សហគមន៍ ដែលរងផលប៉ះពាល់ពីគម្រោងជាប្រចាំអំពីសកម្មភាពសាងសង់របស់គម្រោង ដំណើរការដែលត្រូវអនុវត្តដើម្បីផ្តល់គោលនយោបាយសំណងដល់ដី និងសិទ្ធិពាក់ព័ន្ធ និងនីតិវិធីក្នុងការផ្តល់សំណង/ជួសជុល។

(vii) ធានាថា ប្រជាពលរដ្ឋ និងគ្រួសារដែលរងផលប៉ះពាល់ពីគម្រោងនឹងទទួលបានដំណោះស្រាយ និងមានជម្រើសធនធាន និងថា ដំណោះស្រាយត្រូវស្របតាមគោលការណ៍នានាដែលមានចែងក្នុងក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់ និងជាពិសេស ត្រូវមានការអនុវត្តជាក់ស្តែង។

(viii) ប្រជាពលរដ្ឋ និងគ្រួសារដែលរងផលប៉ះពាល់ពីគម្រោងដោយមិនគិតពីស្ថានភាពផ្លូវច្បាប់លើទ្រព្យសម្បត្តិនឹងទទួលបានការគាំទ្រច្រើនប្រភេទ ដូចមានរៀបរាប់នៅក្នុងតារាងបញ្ជាក់ពីសិទ្ធិលើទ្រព្យសម្បត្តិដើម្បីជួយពួកគេថែរក្សាជីវភាពរស់នៅ និងសុខុមាលភាពក្នុងកម្រិតមួយស្មើនឹងកម្រិតមុនពេលអនុវត្តន៍គម្រោង។ ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់មិនរៀបរយនឹងមិនទទួលបានគោលនយោបាយសំណងលើការបាត់បង់ដីធ្លី ប៉ុន្តែនឹងទទួលបានគោលនយោបាយលើការបាត់បង់ទ្រព្យសម្បត្តិដែលត្រូវបានបង្កើតឡើងមុនកាលបរិច្ឆេទផ្សព្វផ្សាយពីគម្រោង និងគោលនយោបាយចំពោះការបាត់បង់ប្រាក់ចំណូល ដើម្បីជួយឱ្យពួកគេបន្តជីវភាពរស់នៅ និងសុខុមាលភាពរបស់ពួកគេ។ វិធានការលម្អិតសម្រាប់អនុវត្តន៍នឹងត្រូវកំណត់ ដោយផ្អែកលើការឯកភាពគ្នា និងទិន្នន័យមូលដ្ឋាននៃការសិក្សាស្រាវជ្រាវសេដ្ឋកិច្ច-សង្គមដែលបានធ្វើឡើង នៅពេលរៀបចំផែនការសកម្មភាពតាំងទីលំនៅសង្ខេប/ផែនការសកម្មភាពតាំងទីលំនៅ (ARAP/RAP)។

(ix) ប្រជាពលរដ្ឋ និងគ្រួសារដែលរងផលប៉ះពាល់ពីគម្រោងនឹងទទួលបានការជូនដំណឹងពីតារាងពេលវេលាកំណត់សម្រាប់អនុវត្តន៍គម្រោង និងទទួលបានការពិគ្រោះយោបល់ទាក់ទងនឹងគោលការណ៍លទ្ធកម្មដីធ្លី និងការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិ និង

(x) ការបាក់បែក ខូចខាតដល់ទ្រព្យសម្បត្តិ ដូចជា ដំណាំ ដើមឈើ របង និងសំណង់តូចៗ និងការបាត់បង់ប្រាក់ចំណូល (រួមទាំងការបាត់ទិន្នផល) នឹងត្រូវកាត់បន្ថយជាអតិបរមា។ ក្នុងករណីមិនអាច

ចៀសរួច ការខូចខាត ការបាត់បង់ទាំងនោះត្រូវបានគោលនយោបាយសំណង ដោយមិនពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់នៃការកាន់កាប់ អនុលោមតាមតារាងបញ្ជាក់ពីសិទ្ធិលើទ្រព្យសម្បត្តិដូចមានបង្ហាញក្នុងតារាង ២។

១២. **ប្រជាពលរដ្ឋផ្លាស់ទីលំនៅ និងសិទ្ធិ៖** សកម្មភាពសាងសង់របស់គម្រោងអាចមានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានលើប្រជាពលរដ្ឋ ប៉ុន្តែផលប៉ះពាលទាំងនោះមានកម្រិតខុសៗគ្នា អាស្រ័យលើកាលៈទេសៈជាក់ស្តែង។ យើងអាចសន្មត់ដោយមានហេតុផលថា បើទោះបីតំបន់គោលដៅដែលស្នើឡើងនឹងមានផលប៉ះពាល់វិជ្ជមានលើប្រជាពលរដ្ឋយ៉ាងច្រើនក៏ដោយ ក៏បុគ្គលមួយចំនួនប៉ុណ្ណោះនឹងទំនងជារងការប៉ះពាល់អវិជ្ជមានពីសកម្មភាពខ្លះនៃសកម្មភាពសាងសង់ដែលគ្រោងអនុវត្តន៍។ បញ្ហាលើចំណុចនេះគឺត្រូវធ្វើការប៉ាន់ស្មានពីផលប៉ះពាល់អវិជ្ជមាន និងរៀបចំប្រភេទនៃប្រជាពលរដ្ឋផ្លាស់ទីលំនៅ។ ទោះជាយ៉ាងណាក៏ដោយ កត្តាដែលថា តំបន់គោលដៅមួយចំនួនរបស់គម្រោង និងការរៀបចំលម្អិតអំពីកន្លែងដែលត្រូវអនុវត្តន៍គម្រោងមិនទាន់បានដឹងនៅពេលនោះធ្វើឱ្យយើងមានការលំបាកក្នុងការប៉ាន់ស្មានឱ្យបានសមរម្យពីប្រជាពលរដ្ឋដែលត្រូវផ្លាស់ទីលំនៅ ឬពីប្រជាពលរដ្ឋណាដែលនឹងរងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលដើម្បីដាក់បញ្ចូលក្នុងក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់។ ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងអាចត្រូវបានបែងចែកជាបីប្រភេទ និងត្រូវទទួលបានគោលនយោបាយសំណង ដោយផ្អែកលើប្រភេទទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ និងវិសាលភាពនៃផលប៉ះពាល់។ ប្រភេទទាំងបីនៃប្រជាពលរដ្ឋផ្លាស់ទីលំនៅគឺ (១)-ម្ចាស់ដីស្របច្បាប់ (២)-ម្ចាស់ដីដែលមានការទទួលស្គាល់ និង(៣)-អ្នកប្រើប្រាស់ដីគ្មានការទទួលស្គាល់ ឬគ្មានការអនុញ្ញាត។

១៣. **លក្ខខណ្ឌវិនិច្ឆ័យនៃការទទួលបានគោលនយោបាយសំណង៖** ប្រជាពលរដ្ឋ និងគ្រួសារដែលរងផលប៉ះពាល់ពីគម្រោងដែលមានប្រជាជនច្រើនប្រភេទ ក្នុងនោះរួមទាំងជនជាតិដើមភាគតិច ក្រុមជនងាយរងគ្រោះនឹងទទួលបានគោលនយោបាយសំណង និង/ឬ ជំនួយ ប្រសិនបើ (១)-ដីរបស់គេត្រូវបានកាត់បន្ថយច្រើនជាង ៥% នៃទំហំដីសរុប (២)-ប្រភពប្រាក់ចំណូលត្រូវរងការប៉ះពាល់អវិជ្ជមាន (៣)-ផ្ទះរបស់គេត្រូវបានវាយចោលដោយផ្នែក ឬវាយចោលទាំងស្រុង និង (៤)-ទ្រព្យសម្បត្តិផ្សេងៗទៀត (ដូចជាដំណាំ ដើមឈើ និងសំណង់នានា) ឬលទ្ធភាពចូលទៅប្រើប្រាស់ទ្រព្យសម្បត្តិនឹងត្រូវបានកាត់បន្ថយ ឬរងការខូចខាតដោយសារលទ្ធកម្មដី។ កង្វះឯកសារផ្លូវច្បាប់ពីសិទ្ធិប្រើប្រាស់ជាប្រពៃណី ឬវិញ្ញាបនបត្រកាត់កាប់នឹងមិនប៉ះពាល់ដល់សិទ្ធិស្របច្បាប់ក្នុងការទទួលគោលនយោបាយសំណងទេ។

១៤. **ការពិចារណាផ្នែកសង្គម៖** គម្រោងទទួលស្គាល់ថា ក្រុមមនុស្សក្នុងសង្គមមួយចំនួន ក្នុងនោះរួមទាំងជនជាតិដើមភាគតិចអាចមានលទ្ធភាពតិចតួចក្នុងការស្តារកម្រិតជីវភាព ការរស់នៅ និងកម្រិតប្រាក់ចំណូលរបស់ខ្លួន ហើយគម្រោងបានបញ្ចូលបញ្ហាកង្វល់ទាំងនេះទៅក្នុងការរៀបចំ និងការអនុវត្ត

សកម្មភាពគម្រោង តាមរយៈដំណើការនៃការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចដោយមានការចូលរួម។ ក្នុងអំឡុងពេលអនុវត្តន៍ គម្រោងនឹងផ្តោតការយកចិត្តទុកដាក់ពិសេសលើស្ត្រី និងគ្រួសារដែលមានមេគ្រួសារជាស្ត្រី ដោយជ្រើសរើសពួកគេជាអ្នកទទួលផលពីការវិនិយោគរបស់គម្រោង ដូចជា ការជួលឱ្យពួកគេធ្វើការងារសាងសង់ ជាដើម។ ការចូលរួមដោយស្មើភាពគ្នារបស់ស្ត្រីក្នុងវដ្តទាំងមូលនៃសកម្មភាពគម្រោងនឹងត្រូវធ្វើឡើងដើម្បីលើកកម្ពស់ពីលទ្ធភាពនៃនិរន្តរភាពគម្រោង។ គម្រោងនឹងធានាឱ្យមានការចូលរួមយ៉ាងសកម្មរបស់ស្ត្រី និងក្រុមជនជាតិដើមភាគតិច ក្នុងអំឡុងពេលនៃការរៀបចំវិធានការសមស្របដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការជាក់លាក់ ឬកង្វល់របស់ក្រុមទាំងនេះ ដូចជាប្រជាពលរដ្ឋគ្មានដីធ្លី ក្រីក្រ និងគ្រួសារដែលមានស្ត្រីជាមេផ្ទះ ជនពិការ មនុស្សចាស់ ឬកុមារដែលគ្មានមធ្យោបាយគាំទ្រខ្លួនឯង។ យុទ្ធសាស្ត្រយេនឌ័រ និងសកម្មភាពជាក់លាក់សម្រាប់ក្រុមជនជាតិដើមភាគតិចនឹងត្រូវបានរៀបចំឡើង រួចដាក់បញ្ចូលក្នុងផែនការសកម្មភាពតាំងទីលំនៅសង្ខេប/ផែនការសកម្មភាពតាំងទីលំនៅ។

**ដំណើការតាំងទីលំនៅ និងការឯកភាព**

១៥. **ការត្រួតពិនិត្យការពារប្រយោជន៍សង្គម៖** បន្ទាប់ពីមានការឯកភាពលើតំបន់គោលដៅរួចហើយ ការត្រួតពិនិត្យផ្នែកសង្គមនឹងត្រូវបានធ្វើឡើងដោយជនបង្គោលការពារផលប្រយោជន៍សង្គម (SSFP) និង/ឬទីប្រឹក្សានៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីកំណត់ថាតើដីនិង/ឬទ្រព្យសម្បត្តិត្រូវផ្តល់ឱ្យដោយស្ម័គ្រចិត្ត ត្រូវបានផ្លាស់ប្តូរទីតាំង ឬត្រូវតាំងទីលំនៅដោយមិនស្ម័គ្រចិត្តនិង/ឬ បញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងសកម្មភាពសាងសង់ដែលត្រូវអនុវត្តន៍ទៅតាមផែនការនីមួយៗ។ ជាលទ្ធផល ផែនការសកម្មភាពតាំងទីលំនៅសង្ខេប ឬផែនការសកម្មភាពតាំងទីលំនៅនឹងត្រូវរៀបចំឡើងសម្រាប់តំបន់គោលដៅដែលមានផលប៉ះពាល់អវិជ្ជមានដោយសា រការផ្លាស់ប្តូរទីលំនៅដោយមិនស្ម័គ្រចិត្តទាំងរយៈពេលខ្លី ឬអចិន្ត្រៃយ៍។ ក្រៅពីផែនការសកម្មភាពតាំងទីលំនៅសង្ខេប/ផែនការសកម្មភាពតាំងទីលំនៅ គម្រោងនឹងរៀបចំរបាយការណ៍ពីការយកចិត្តទុកដាក់កម្រិតខ្ពស់ (DDR) សម្រាប់តំបន់គោលដៅដែលគ្មានផលប៉ះពាល់នៃការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត និង/ឬទីតាំងដែលសហគមន៍ ឬប្រជាពលរដ្ឋផ្តល់ដីដោយស្ម័គ្រចិត្ត។ សម្រាប់ការធ្វើផែនការដែលមានប្រសិទ្ធភាព ការត្រួតពិនិត្យគួរធ្វើឡើងឱ្យបានលឿនបំផុតតាមដែលអាចធ្វើបាន និងនៅមុនពេលដំណើរការរៀបចំ ផែនការសកម្មភាពតាំងទីលំនៅ ដើម្បីឱ្យជនបង្គោលការពារផលប្រយោជន៍សង្គមបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីរៀបចំផែនការសកម្មភាពតាំងទីលំនៅសង្ខេប/ផែនការសកម្មភាពតាំងទីលំនៅ ឬរបាយការណ៍ពីការយកចិត្តទុកដាក់កម្រិតខ្ពស់សម្រាប់ការផ្តល់ដីដោយស្ម័គ្រចិត្តសម្រាប់តំបន់គោលដៅនីមួយៗ។

១៦. **ការរៀបចំផែនការសកម្មភាពតាំងទីលំនៅសង្ខេប/ផែនការសកម្មភាពតាំងទីលំនៅ និងការឯកភាព៖** ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូនដោយសហការជាមួយនឹងអគ្គ

នាយកដ្ឋានដោះស្រាយផលប៉ះពាល់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាលេខាធិការដ្ឋាននៃគណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួងផ្តល់ការណែនាំទូទៅសម្រាប់រៀបចំផែនការ ការងារដោះស្រាយផលប៉ះពាល់ និងដំណើរការលទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត ធានាឱ្យមានការសម្របសម្រួលរវាងភាគីផ្សេងៗ ទាក់ទងនឹងគម្រោង ក្នុងនោះរួមទាំងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយផ្ទាល់ពីការផ្លាស់ប្តូរទីតាំង និងសកម្មភាពត្រួតពិនិត្យ។ មុននឹងចាប់ផ្តើមសាងសង់របស់គម្រោង ភាគីពាក់ព័ន្ធពីតំបន់គោលដៅដែលអាចមានផលប៉ះពាល់ពី ការផ្លាស់ប្តូរទីលំនៅនឹងត្រូវបានពិភាក្សា ដើម្បីបង្កើតគោលការណ៍ក្នុងការរៀបចំផែនការ និងការរៀបចំការងារក្នុងគោលបំណងដើម្បីកំណត់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានផ្នែកសង្គមដោយសារតែសកម្មភាពសាងសង់។ ផែនការសកម្មភាពតាំងទីលំនៅសង្ខេប/ផែនការសកម្មភាពតាំងទីលំនៅនឹងត្រូវផ្អែកលើព័ត៌មានពី ទិន្នន័យនៃការសិក្សាបឋម ការវាយតម្លៃទ្រព្យសម្បត្តិ និងការកំណត់ទាក់ទងនឹងគោលនយោបាយសំណង ទោះបីស្ថិតក្នុងបរិបទនៃការផ្លាស់ប្តូរទីលំនៅបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ក៏ដោយ និងគោលនយោបាយសំណង ឬក្នុងបរិបទនៃការកាត់បន្ថយផលប៉ះពាល់សង្គមផ្សេងៗទៀត បណ្តាលមកពីការអនុវត្តគម្រោង។ តំបន់គោលដៅរបស់គម្រោងដែលប៉ះពាល់ប្រជាពលរដ្ឋលើសពី ២០០ នាក់ ពោលគឺបាត់បង់ទ្រព្យសម្បត្តិ និងជីវភាពរស់នៅ ចាំបាច់ត្រូវធ្វើផែនការសកម្មភាពតាំងទីលំនៅ។ ជាអនុសាសន៍ផែនការសកម្មភាពតាំងទីលំនៅសង្ខេប/ផែនការសកម្មភាពតាំងទីលំនៅនឹងត្រូវរៀបចំដោយផ្អែកលើតំបន់ ឬកញ្ចប់កិច្ចសន្យា ដែលជាកន្លែងត្រូវអនុវត្តន៍សកម្មភាពគម្រោង។ ទង្វើដូច្នេះនឹងនាំឱ្យមានការអនុវត្ត និងត្រួតពិនិត្យ ផែនការសកម្មភាពតាំងទីលំនៅសង្ខេប/ផែនការសកម្មភាពតាំងទីលំនៅបានកាន់តែប្រសើរ។ ផែនការសកម្មភាពតាំងទីលំនៅសង្ខេប/ផែនការសកម្មភាពតាំងទីលំនៅនឹងត្រូវរៀបចំឡើងដោយជនបង្គោលផ្នែកសុវត្ថិភាពសង្គមរបស់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន និងដាក់ជូន គណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួង/អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ពិនិត្យ និងឯកភាពមុននឹងបញ្ជូនទៅធនាគារពិភពលោក។ ដោយសារក្រសួងសាធារណការ និងដឹកជញ្ជូនជាស្ថាប័នសម្របសម្រួលដឹកនាំគម្រោង ស្ថាប័ននេះនឹងទទួលខុសត្រូវ ប្រមូល និងបូកសរុបឯកសារ ផ្នែកសុវត្ថិភាពសង្គមពាក់ព័ន្ធទាំងអស់សម្រាប់ដាក់ជូន គណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួង/អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ និងធនាគារពិភពលោក ក្នុងនាមគម្រោង។

## នីតិវិធីរៀបចំសម្រាប់ការតាំងទីលំនៅ

១៧. ការអនុវត្តក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់នឹងត្រូវធ្វើឡើង ដោយផ្អែកលើការរៀបចំអនុវត្តន៍គម្រោង។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូននឹងបង្កើតអង្គភាពគ្រប់គ្រងសមាសភាគរបស់គម្រោង (អង្គភាពគ្រប់គ្រងសមាសភាគទី១ និងអង្គភាពគ្រប់គ្រងសមាសភាគទី ២) សម្រាប់ការអនុវត្តសមាសភាគទី១ និងសមាសភាគទី២ របស់គម្រោង។ អង្គភាពគ្រប់គ្រងសមាសភាគទាំងពីរ នឹងដឹកនាំការអនុវត្តគម្រោងប្រចាំថ្ងៃ ទទួលខុសត្រូវខ្ពស់លើការងារដូច

ជា ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម ត្រួតពិនិត្យវឌ្ឍនភាពគម្រោង និងធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ធានាឱ្យមានការអនុវត្តការងារស្របតាមលក្ខខណ្ឌការពារបរិស្ថាន និងសង្គម រៀបចំរបាយការណ៍គម្រោង ត្រួតពិនិត្យការងារសំណង់ស៊ីវិល សម្របសម្រួលនិងប្រមូលរបាយការណ៍ពីក្រសួងស្ថាប័នពាក់ព័ន្ធទាក់ទង នឹងផ្នែករបស់ខ្លួន។

១៨. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូននឹងចាត់តាំងជន បង្គោលសុវត្ថិភាពបរិស្ថាន និងសង្គម ចំនួន ៤រូប ឱ្យទទួលខុសត្រូវលើការអនុវត្តតាមលក្ខខណ្ឌសុវត្ថិភាព បរិស្ថាន និងសង្គម ដូចមានចែងក្នុងក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់ដែល បានទទួលការឯកភាពគ្នា និងផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ប្រសិនបើមាន។ ដោយមានការ គាំទ្រពីទីប្រឹក្សាបច្ចេកទេសសុវត្ថិភាពសង្គមម្នាក់ដែលនឹងត្រូវជ្រើសរើសដើម្បីជួយដល់សមាសភាគទាំងពីរ របស់គម្រោង ជនបង្គោលសុវត្ថិភាពសង្គម នឹងទទួលខុសត្រូវលើ (ក)-ការអនុវត្តសកម្មភាពដូចមាន កំណត់ក្នុងក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់ (ខ)-រៀបចំកិច្ចប្រជុំពិគ្រោះ យោបល់សាធារណៈ និងការវាយតម្លៃសង្គមដើម្បីកំណត់ពីតម្រូវការនៃទីតាំងដាក់លាក់របស់អនុគម្រោង ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានបណ្តាលមកពី ការអនុវត្តអនុគម្រោងនៅតាមទីតាំងដាក់លាក់ និងអន្តរាគមន៍ដែលអាចមានពីគម្រោង (គ)-រៀបចំកំណត់ហេតុ នៃកិច្ចប្រជុំដោយរៀបចំលម្អិតពីការ ផ្សព្វផ្សាយព័ត៌មាន បញ្ហាដែលបានពិភាក្សា កង្វល់ដែលលើកឡើងដោយ ប្រជាពលរដ្ឋដែលរងផលប៉ះ ពាល់ពីគម្រោង និងអន្តរាគមន៍គម្រោងដែលអាចកើតមាន និង (ឃ)-រៀបចំកិច្ចពិគ្រោះយោបល់ វាយតម្លៃ ផ្នែកសង្គមដែលបានធ្វើបច្ចុប្បន្នភាព និងរៀបចំរបាយការណ៍។ លទ្ធផលនៃកិច្ចការនឹងត្រូវសង្ខេបជារបាយ ការណ៍ និងបញ្ជូនទៅអង្គភាពគ្រប់គ្រងផ្នែក ដែលនឹងត្រូវចងក្រងជារបាយការណ៍ និងដាក់ជូនធនាគារ តាមរយៈអង្គភាពសម្របសម្រួលគម្រោង (PCU)។

១៩. **រដ្ឋបាលខេត្ត និងមន្ទីរសាធារណការ និងដឹកជញ្ជូន៖** មន្ទីរនៅថ្នាក់ក្រោមជាតិរបស់ក្រសួង ឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន គឺជាទំនាក់ទំនងរវាង ក្រសួងសាមីនិង អាជ្ញាធរមូលដ្ឋាន/សហគមន៍មូលដ្ឋាន។

២០. **ទីប្រឹក្សាបច្ចេកទេសសុវត្ថិភាពសង្គម** ដែលតំណែងនេះមានថវិកាក្នុង ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និង សង្គម នឹងត្រូវជ្រើសរើសឱ្យបំពេញការងារដើម្បីជួយជនបង្គោលផ្នែកសុវត្ថិភាពសង្គមដោយធ្វើការធានាថា ការវាយតម្លៃផ្នែកសង្គមត្រូវបានធ្វើចប់រួចរាល់ ក្នុងនោះរួមទាំងកិច្ចពិគ្រោះយោបល់ដោយសេរីជាមុន និង ជាកិច្ចពិគ្រោះយោបល់ដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ និងធានាថា ផែនការសកម្មភាពតាំងទីលំនៅ នៅ ពេលចាំបាច់ ត្រូវបានរៀបចំធ្វើឡើង និងអនុវត្តន៍។

២១. **គណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួង (IRC)** គឺជាស្ថាប័នរំលែកអំណាចមួយដែលដឹកនាំដោយតំណាងមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរួមមានតំណាងមកពីក្រសួងពាក់ព័ន្ធដូចជាក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ដោយត្រូវបានបង្កើតឡើងដោយ នាយករដ្ឋមន្ត្រីតាមរយៈសេចក្តីសម្រេចលេខ ១៣ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៧ ទាក់ទងនឹងការបម្លាស់ទីលំនៅនៃគ្រួសារប៉ះពាល់ នៅក្នុងគម្រោងផ្លូវហាយវេលេខ១ (កម្ចី ១៦៥៩-CAM) គណៈកម្មាធិការនេះបន្តចូលរួមនៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋាភិបាលដែលមានជំនួយពីបរទេសផ្សេងទៀតដែលមានការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។ គណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួងមួយនឹងត្រូវបង្កើតឡើងក្នុងករណីពិសេសសម្រាប់គម្រោងនីមួយៗ តាមការស្នើសុំពីភ្នាក់ងារអនុវត្តន៍គម្រោង ឬភ្នាក់ងារប្រត្តិបត្តិគម្រោង គឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន។ គណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួងនេះនឹងសន្មត់មុខងារនៃស្ថាប័នបង្កើតថ្មីដោយធានាថាថវិកាសម្រាប់ការដោះស្រាយផលប៉ះបាល់ត្រូវបានចំណាយត្រឹមត្រូវ និងធានាថា ក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់-ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ត្រូវបានអនុវត្តន៍តាមគោលបំណង។ ផ្នែកបច្ចេកទេសរបស់គណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួង គឺលេខាធិការដ្ឋានរបស់ខ្លួន គឺអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២២. **អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់(GDR)** គឺជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួង ហើយនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័នពាក់ព័ន្ធផ្សេងទៀតដើម្បីដោះស្រាយរាល់បញ្ហានៃការតាំងទីលំនៅដែលកើតចេញពីគម្រោង។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់កំពុងដើរតួនាទីឈានមុខនៅក្នុងការអនុវត្ត ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់។

២៣. **អនុគណៈកម្មាធិការតាំងទីលំនៅថ្នាក់ខេត្ត (PRSC)៖** អនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត គឺជាស្ថាប័នរំលែកអំណាចមួយដែលបង្កើតឡើងនៅថ្នាក់ខេត្ត។ ក្រោមការដឹកនាំពីអភិបាលខេត្ត ឬអភិបាលរងខេត្ត សមាជិកនៃអនុគណៈកម្មាធិការនេះរួមមាន ប្រធានមន្ទីរនៃក្រសួងពាក់ព័ន្ធ ដែលតំណាងនៅក្នុងគណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួង និងរួមទាំងចៅហ្វាយស្រុក និងមេឃុំនៅក្នុងតំបន់ដែលរងប៉ះពាល់ដោយគម្រោងផងដែរ។

## ភ្ជាប់ការតាំងទីលំនៅទៅនឹងការងារពលរដ្ឋ

២៤. ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង និងគ្រួសារដែលរងផលប៉ះពាល់ពីគម្រោងទាំងអស់ដោយមិនគិតពីស្ថានភាពស្របច្បាប់នៃទ្រព្យសម្បត្តិ នឹងទទួលបានការគាំទ្រគ្រប់ប្រភេទតាមគោលការណ៍ដែលបានកំណត់នៅក្នុងតារាងសិទ្ធិទទួលបាន ដើម្បីជួយពួកគេក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាជីវភាពរស់នៅ

និងស្តង់ដាររស់នៅរបស់ពួកគេដែលមានស្រាប់នៅមុនគម្រោង។ អ្នកចាប់ដីខុសច្បាប់នឹងមិនត្រូវបានទូទាត់សំណងចំពោះការបាត់បង់ដីទេ ប៉ុន្តែនឹងទទួលបានសំណងចំពោះការបាត់បង់ទ្រព្យសម្បត្តិផ្សេងទៀតដែលត្រូវបានបង្កើតឡើងដោយហិរញ្ញវត្ថុផ្ទាល់ខ្លួនរបស់ពួកគេ និងការបាត់បង់ប្រាក់ចំណូល ក្នុងរបៀបដែលពួកគេត្រូវបានជួយក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីរក្សាជីវភាពរស់នៅ និងសុខុមាលភាពរបស់ពួកគេ។ វិធានការលម្អិតដែលត្រូវអនុវត្តន៍នឹងត្រូវបានកំណត់ដោយផ្អែកលើជំរឿន និងការស្ទង់មតិសេដ្ឋកិច្ចសង្គមដែលបានធ្វើឡើងនៅពេលដែល ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប/ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ត្រូវបានបង្កើតឡើង។ សំណងទូទាត់នឹងត្រូវបានទូទាត់ដោយការចំណាយ/តម្លៃជំនួសចំពោះ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងរៀងៗខ្លួន យ៉ាងហោចណាស់ ៣០ថ្ងៃ មុនពេលចាប់ផ្តើមការសាងសង់ដើម្បីឱ្យប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង មានពេលវេលាគ្រប់គ្រាន់ដើម្បីដកចេញ ឬផ្លាស់ទីរចនាសម្ព័ន្ធដែលរងផលប៉ះពាល់។ ដូចគ្នានេះដែរ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង នឹងត្រូវបានជូនដំណឹង ៣០ ថ្ងៃមុនពេលចាប់ផ្តើមការសាងសង់។

២៥. **ដំណើរការអនុវត្ត ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប/ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់៖** បន្ទាប់ពីការស្នើសុំការអនុវត្ត ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប/ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ដោយ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន គណៈកម្មាធិការតាំងទីលំនៅអន្តរក្រសួង នឹងប្រមូលផ្តុំក្រុមការងាររបស់ខ្លួនដើម្បីធ្វើការយ៉ាងជិតស្និទ្ធជាមួយ ក្រុមការងារអនុគណៈកម្មាធិការសម្របសម្រួលការងារដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត (អនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត-ក្រុមការងារ) មុនពេលចាប់ផ្តើមការតាំងទីលំនៅ។ ការទិញដីធ្លី និងការផ្លាស់ប្តូរទីលំនៅរបស់គ្រួសារដែលរងផលប៉ះពាល់ពីគម្រោង នឹងមិនត្រូវបានចាប់ផ្តើមទេរហូតដល់ ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់លម្អិតត្រូវបានពិនិត្យ និងអនុម័តដោយគណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួង និងធនាគារពិភពលោក។ ជំហានមួយចំនួនមានសារៈសំខាន់ចំពោះដំណើរការអនុវត្ត ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប/ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ រួមមាន៖ (i)-ការស្ទង់វាស់វែងលម្អិត (DMS) និងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចមូលដ្ឋាន(BSS) (ii)-ការសិក្សាតម្លៃចំណាយជំនួស (RCS) (iii)-ការរៀបចំ និងការអនុម័ត ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប/ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ (iv)-ការរៀបចំ និងការអនុម័តថវិកាដោះស្រាយផលប៉ះពាល់ (v)-ការចុះកិច្ចសន្យា និងការទូទាត់សំណង (vi)-ព័ត៌មានសាធារណៈ ការពិគ្រោះយោបល់ និងការបង្ហាញព័ត៌មាន និង (vii)-សេចក្តីជូនដំណឹងស្តីពីការសម្អាតទីតាំង។

## តម្លាភាព និងយន្តការដោះស្រាយបណ្ដឹង

២៦. គោលនយោបាយដោះស្រាយផលប៉ះពាល់របស់ធនាគារពិភពលោកតម្រូវឱ្យគម្រោង បង្កើតយន្តការដោះស្រាយបណ្ដឹងតវ៉ាដើម្បីធានា ការពេញចិត្តរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងចំពោះការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការតាំងទីលំនៅ ហើយផ្ដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង នូវកម្មវិធីស្របច្បាប់ ដើម្បីតាមដាន និងធ្វើរបាយការណ៍ស្ដីពីការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការតាំងលំនៅ។ ជាក់ស្ដែងគោលបំណងនៃ យន្តការដោះស្រាយបណ្ដឹងគឺដើម្បីអនុញ្ញាតឲ្យ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង និងបុគ្គលដែលជឿជាក់ថាពួកគេទទួលរងផលប៉ះពាល់ ក្នុងការស្វែងរកដំណោះស្រាយចំពោះបណ្ដឹងដែលពួកគេអាចមានពាក់ព័ន្ធនឹងលទ្ធភាពទទួលដីធ្លី ឬអន្តរាគមន៍របស់គម្រោងផ្សេងទៀត។

២៧. នៅចាប់ផ្ដើមនៃការអនុវត្តគម្រោងនេះ គណៈកម្មាធិការដោះស្រាយបណ្ដឹងនឹងត្រូវបានបង្កើតឡើងនៅថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ខេត្ត ដោយផ្អែកលើរចនាសម្ព័ន្ធដែលមានស្រាប់រួមមានមន្ទីរពាក់ព័ន្ធ អង្គការសហគមន៍ តំណាងជនជាតិដើមភាគតិច និងស្ត្រី ប្រសិនបើពួកគេមាន។ នៅថ្នាក់ភូមិ យន្តការដោះស្រាយបណ្ដឹងដែលមានស្រាប់ ដែលត្រូវបានដឹកនាំដោយចាស់ទុំ និង/ឬអ្នកដឹកនាំសាសនា ដែលអាចទទួលយកបានយ៉ាងទូលំទូលាយសម្រាប់សហគមន៍មូលដ្ឋាន នឹងត្រូវបានពង្រឹងជាយន្តការដោះស្រាយជម្លោះជំហានដំបូង។ ការរៀបចំនេះជួយធានាថា មានប្រព័ន្ធមួយដើម្បីជួយដោះស្រាយបញ្ហាណាមួយ ឬពាក្យបណ្ដឹងដែលអាចកើតឡើងបន្ទាប់ពីអន្តរាគមន៍របស់គម្រោង។ យន្តការដោះស្រាយបណ្ដឹងនឹងត្រូវអនុវត្តចំពោះបុគ្គល ឬក្រុមដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលពីគម្រោង ក៏ដូចជាអ្នកដែលមានចំណាប់អារម្មណ៍ចំពោះ គម្រោង និង/ឬមានលទ្ធភាពដើម្បីជះឥទ្ធិពលលើលទ្ធផលរបស់គម្រោងទាំងវិជ្ជមាន និងអវិជ្ជមាន។ គម្រោងនេះនឹងផ្ដល់នូវការបណ្ដុះបណ្ដាល និងការគាំទ្រដើម្បីពង្រឹងរចនាសម្ព័ន្ធដែលមានស្រាប់ទាំងនេះសម្រាប់ការដោះស្រាយដែលមានប្រសិទ្ធភាព និងមានលក្ខណៈប្រមូលផ្ដុំ ចំពោះបណ្ដឹងអាចលើកឡើងដោយ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង ក្នុងកំឡុងពេល និងបន្ទាប់ពីការអនុវត្តសកម្មភាពដែលទាក់ទងនឹងការងារដោះស្រាយផលប៉ះពាល់។

## ថវិកា និងតម្លៃការងារដោះស្រាយផលប៉ះពាល់

២៨. ថវិកាសម្រាប់អនុវត្តក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់ នឹងជាផ្នែកមួយនៃថវិកាគម្រោង។ ថវិកានេះត្រូវបានប្រើប្រាស់សម្រាប់ទូរទាត់លើការចំណាយលើប្រាក់ឧបត្ថម្ភដល់បុគ្គលិកគម្រោង និងទីប្រឹក្សាបច្ចេកទេសក្នុងការរៀបចំរបាយការណ៍អនុវត្តន៍ការងារ រួមទាំងរបាយការណ៍គ្រប់គ្រង និងត្រួតពិនិត្យ ការប្រមូលទិន្នន័យ និងការរៀបចំផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប/ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ។ល។ ថវិកាសរុបសម្រាប់អនុវត្តក្របខណ្ឌគោល

នយោបាយការងារដោះស្រាយផលប៉ះពាល់ ត្រូវបានប៉ាន់ស្មាន និងមានបង្ហាញក្នុង ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម។

២៩. នៅក្នុងដំណើរការរៀបចំ ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប/ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ នោះ ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប/ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់នីមួយៗនឹងត្រូវដាក់បញ្ចូលការចំណាយលម្អិតសម្រាប់គោលនយោបាយសំណង និងសិទ្ធិនៃការស្តារឡើងវិញដែលជាផ្នែកមួយនៃដំណើរការក្នុងការផ្តល់សំណងដល់ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង និងគ្រួសារដែលរងផលប៉ះពាល់ពីគម្រោង។ ការរៀបចំនានានឹងត្រូវបានធ្វើឡើងសម្រាប់ទ្រព្យសម្បត្តិ និងធនធានរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង និងគ្រួសារដែលរងផលប៉ះពាល់ពីគម្រោងដែលត្រូវបានញែកពីគ្នាដោយផ្អែកលើដីកសិកម្ម ដីលំនៅឋាន ដីប្រកបអាជីវកម្ម ផ្ទះ ទ្រព្យសម្បត្តិអាជីវកម្ម និងកម្មសិទ្ធិផ្សេងៗទៀត។ ការប៉ាន់ស្មានពីថវិកាលម្អិតនឹងអាចត្រៀមថវិកាគ្រប់គ្រាន់សម្រាប់ចំណាយផ្សេងៗ ហើយ ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ នឹងបង្ហាញយ៉ាងច្បាស់លាស់ពីប្រភពមូលនិធិទាំងអស់ដែលត្រូវការចាំបាច់។ ផែនការសកម្មភាពតាំងទីលំនៅនឹងធានាថាលំហូរថវិកាត្រូវមានភាពស្របគ្នានឹងតារាងពេលវេលាបើក គោលនយោបាយសំណង និងការផ្តល់ជំនួយផ្សេងៗទៀត។ ថវិកាទាំងនេះនឹងប្រើសម្រាប់លទ្ធកម្មដី ការផ្លាស់ប្តូរទីតាំងអភិវឌ្ឍន៍ ការចំណាយលើគោលនយោបាយសំណង ប្រាក់ឧត្តម្ភ និងការចំណាយផ្នែករដ្ឋបាល និងប្រាក់បម្រុង។ ការចំណាយលើការតាំងទីលំនៅនឹងជាផ្នែកមួយនៃ ថវិកាសមភាគីរបស់រដ្ឋាភិបាល មិនប្រើថវិកាគម្រោងនោះទេ។ រដ្ឋាភិបាលនឹងធានាឱ្យមានការផ្តល់ថវិកាសមភាគីសម្រាប់ ការការងារដោះស្រាយផលប៉ះពាល់ទាន់ពេលវេលាក្នុងការបំពេញកាតព្វកិច្ចដែលបានប៉ាន់ស្មានបន្ថែមនឹងការប៉ាន់ស្មានថវិកាសម្រាប់ ការងារដោះស្រាយផលប៉ះពាល់ដើម្បីបំពេញលក្ខខណ្ឌ និងគោលបំណងនៃការងារដោះស្រាយផលប៉ះពាល់។ ការចំណាយសម្រាប់ការការងារដោះស្រាយផលប៉ះពាល់ និងការចំណាយសម្រាប់សិទ្ធិស្តារឡើងវិញផ្សេងៗទៀតនឹងត្រូវគណនាក្នុងអំឡុងពេលអនុវត្តគម្រោង ដោយហេតុថាផែនការអនុវត្តន៍ការងារពិតប្រាកដពុំទានបានកំណត់នៅឡើយ។ ក្នុងពេលនេះការសិក្សាលម្អិតមិនទាន់បានបញ្ចប់នៅឡើយ។ ការចំណាយទាំងនេះនឹងត្រូវទូទាត់តាមរយៈថវិការបស់រាជរដ្ឋាភិបាលកម្ពុជា ហើយថវិកាឥណទាន IDA នឹងមិនត្រូវបានប្រើប្រាស់ក្នុងគោលបំណងនេះឡើយ។

## ការពិគ្រោះសាធារណៈ និងការផ្សព្វផ្សាយព័ត៌មាន

៣០. **គោលនយោបាយធនាគារពិភពលោកស្តីពីការទទួលបានព័ត៌មាន៖** ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មានសាធារណៈដែលមានកំណត់ក្នុងលក្ខខណ្ឌធនាគារពិភពលោក ចាំបាច់ត្រូវផ្តល់ឱ្យសាធារណជន ពីព័ត៌មានគម្រោង និងឯកសារគម្រោង។ ចំណុចនេះតម្រូវអោយមានការពិគ្រោះយោបល់

ជាមួយអ្នកទទួលផល ក្រុមអ្នកប៉ះពាល់ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន ក្នុងអំឡុងពេលនៃការរៀបចំផែនការ និងដំណើរការរៀបចំគម្រោង ហើយផ្អែកបរិស្ថាន និងសង្គមរបស់គម្រោងត្រូវលើកមកបង្ហាញ។ ការពិគ្រោះយោបល់គួរតែជាដំណើរជាប្រចាំ ក្នុងអំឡុងពេលទាំងមូលនៃការរៀបចំ និងអនុវត្តការវិនិយោគ និងចាំបាច់ត្រូវគោរពជាធរមានតាមគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គមទាំងអស់។ គោលនយោបាយក៏តម្រូវផងដែរ អោយឧបករណ៍ពាក់ព័ន្ធទាំងអស់ ដូចជាការសិក្សាវាយតម្លៃបរិស្ថាន ការវាយតម្លៃសង្គម ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ។ល។ គួរតែផ្សព្វផ្សាយឱ្យទាន់ពេលវេលា ហើយប្រើប្រាស់ភាសាដែលប្រើដោយប្រជាពលរដ្ឋក្នុងពេលពិគ្រោះយោបល់។

៣១. **ការពិគ្រោះយោបល់៖** នៅក្នុងបរិបទគម្រោង ក្រោមសមាសភាគទី ១ ការប្រជុំពិគ្រោះយោបល់សាធារណៈត្រូវបានធ្វើឡើងនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨។ មួយសប្តាហ៍មុនកាលបរិច្ឆេទប្រជុំពិគ្រោះយោបល់ អង្គភាពទឹកស្អាតបានចែកលិខិតអញ្ជើញ ទៅកាន់ភាគីពាក់ព័ន្ធ ក្នុងនោះរួមទាំងតំណាងអាជ្ញាធរខេត្ត មន្ទីរជំនាញពាក់ព័ន្ធក្នុងខេត្ត និងសាលាឃុំពាក់ព័ន្ធ។ ប្រជាពលរដ្ឋក្នុងសហគមន៍ រួមទាំងជនជាតិដើមភាគតិច ក្នុងតំបន់អនុវត្តន៍គម្រោង ក៏ត្រូវបានអញ្ជើញឱ្យចូលរួមផងដែរ។ ដូច្នេះ ក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់ត្រូវបានរៀបចំឡើងដោយផ្អែកលើ លទ្ធផលនៃកិច្ចប្រជុំពិភាក្សាទាំងនេះ។ តំណាងមកពី ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង ត្រូវបានបញ្ចូលជាសមាជិកនៃ (១)- គណៈកម្មាធិការសហគមន៍/ភូមិ និង (២)-គណៈកម្មាធិការដោះស្រាយសំណងរបស់គម្រោង។

៣២. **ការផ្សព្វផ្សាយព័ត៌មាន៖** ឯកសារ ក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់ រួមទាំងឯកសារគម្រោង នឹងត្រូវបង្ហក្នុង InfoShop របស់ធានាគារពិភពលោក រួមទាំងគេហទំព័ររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន នៅថ្ងៃទី .......................... ។ ផែនការសកម្មភាពតាំងទីលំនៅសង្ខេប/ផែនការសកម្មភាពតាំងទីលំនៅ ប្រសិនបើមានការរៀបចំ នឹងត្រូវបានបកប្រែទៅជាភាសាមូលដ្ឋាន (ខ្មែរ) និងបង្ហោះក្នុងគេហទំព័រគម្រោង ប្រសិនបើមាន បើមិនដូច្នេះទេ ទៅក្នុងគេហទំព័ររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន និងបញ្ជូនឯកសារថតចម្លងមួយច្បាប់ទៅកាន់ក្រុមប្រឹក្សាឃុំនីមួយៗ ដែលមានការតាំងទីលំនៅមិនស្ម័គ្រចិត្ត។

## ការត្រួតពិនិត្យ និងការធ្វើរបាយការណ៍

៣៣. ការអនុវត្តក្របខណ្ឌគោលនយោបាយការងារដោះស្រាយផលប៉ះពាល់ នៅតាមទីតាំងជាក់លាក់នឹងត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យយ៉ាងទៀងទាត់ ដោយ ជនបង្គោលសុវត្ថិភាពសង្គមនីមួយៗ ដោយមានការពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយនឹងទីប្រឹក្សាបច្ចេកទេសសុវត្ថិភាពសង្គមដែលទទួលខុសត្រូវអុវត្តន៍សកម្មភាពវិនិយោគដែលទាក់ទងនឹងលទ្ធកម្មដី។ លទ្ធផលរកឃើញ និងអនុសាសន៍នឹងត្រូវបានកត់ត្រា នៅក្នុងឯកសារគម្រោងសម្រាប់ពិនិត្យពីសំណាក់ធនាគារពិភពលោក។ ជនបង្គោលសុវត្ថិភាពសង្គម

នឹងគ្រប់គ្រង និងត្រួតពិនិត្យដំណើរការយ៉ាងតិចណាស់ ម្តងក្នុងមួយឆ្នាំ និងដាក់បញ្ចូលលទ្ធផលក្នុងរបាយការណ៍គម្រោងប្រចាំឆ្នាំ ដែលត្រូវបញ្ជូនទៅធនាគារពិភពលោក។ ជនបង្គោលសុវត្ថិភាពសង្គម ដោយសហការជិតស្និទ្ធជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង និងបង្កើតសូចនាករត្រួតពិនិត្យជាក់ស្តែងមួយចំនួន។ ក្នុងករណីមានការរៀបចំ និងអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សង្ខេប/ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ចាំបាច់ត្រូវមានការត្រួតពិនិត្យខាងក្នុង និងខាងក្រៅ ដើម្បីធានាឱ្យមានតម្លាភាព និងការគោរពតាមគោលការណ៍ឱ្យបានពេញលេញ។

៣៤. **ការត្រួតពិនិត្យខាងក្នុង៖** អង្គភាពគ្រប់គ្រងផ្នែកដោយសហការជាមួយនឹង អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់-គណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួង នឹងធ្វើការត្រួតពិនិត្យផ្ទៃក្នុងលើការអនុវត្តការងារដោះស្រាយផលប៉ះពាល់។ ការត្រួតពិនិត្យនេះរួមបញ្ចូលទាំងរបាយការណ៍វឌ្ឍនភាព ស្ថានភាពនៃការអនុវត្ត ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ព័ត៌មានអំពីទីតាំង និងចំនួនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ចំនួនគោលនយោបាយសំណងដែលត្រូវចំណាយតាមមុខនីមួយៗ និងជំនួយផ្សេងៗទៀតដែលត្រូវផ្តល់ឱ្យខ្នងផ្ទះដែលរងផលប៉ះពាល់ពីគម្រោង។ របាយការណ៍នៃលទ្ធផលត្រួតពិនិត្យនឹងត្រូវបានរៀបចំដោយ ជនបង្គោលសុវត្ថិភាពសង្គម និងត្រូវបញ្ជូនទៅ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន និងធនាគារពិភពលោកប្រចាំត្រីមាស និងចម្លងជូនគណៈកម្មាធិការដោះស្រាយផលប៉ះពាល់អន្តរក្រសួង។

៣៥. **ការត្រួតពិនិត្យខាងក្រៅ៖** អ្នកត្រួតពិនិត្យខាងក្រៅមានការទទួលខុសត្រូវដាក់លាក់ក្នុងការសិក្សា និងរាយការណ៍ពីការអនុវត្ត ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់គ្រួសារដែលរងផលប៉ះពាល់ពីគម្រោង ជាពិសេសទាក់ទងនឹង ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង ឬការរំខានដែលបង្ករឡើងដោយការងារសាងសង់ ក្នុងនោះរួមទាំងលំនៅឋានទាំងអស់ដែលផ្ទះហាងទំនិញ ឬតូបលក់ទំនិញរបស់ពួកគេត្រូវបានផ្លាស់ប្តូរទីតាំង។ ការត្រួតពិនិត្យពីខាងក្រៅក៏មានទំនួលខុសត្រូវក្នុងការពិនិត្យឯកសារសក្តានុពលផ្តល់ឱកាសការងារដល់ គ្រួសារដែលរងផលប៉ះពាល់ពីគម្រោង ក្នុងនោះរួមទាំងស្ត្រី និងយុវជនដែលគួរទទួលបានការគាំទ្រពីអាជ្ញាធរខេត្ត។ ប្រសិនបើចាំបាច់គណៈកម្មាធិការអន្តរក្រសួង ត្រូវជួលសេវាអ្នកត្រួតពិនិត្យខាងក្រៅ ដើម្បីត្រួតពិនិត្យ និងធ្វើការវាយតម្លៃខាងក្រៅ ក្របខណ្ឌការងារលម្អិតរបស់អ្នកត្រួតពិនិត្យ និងវាយតម្លៃ បានពង្រាងទុកសម្រាប់ជ្រើសរើសនៅពេលអនុវត្តន៍គម្រោង។ របាយការណ៍ត្រួតពិនិត្យខាងក្រៅប្រចាំត្រីមាស នឹងដាក់ជូន គណៈកម្មាធិការអន្តរក្រសួង។ បន្ទាប់មក គណៈកម្មការអន្តរក្រសួង និងបញ្ជូនទៅក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងធនាគារពិភពលោក។ ការវាយតម្លៃក្រោយការអនុវត្ត នឹងធ្វើឡើង ៦ខែ បន្ទាប់ពីការងារដោះស្រាយផលប៉ះពាល់ត្រូវបានបញ្ចប់។